# អត្ថបទវិភាគខ្លី ៖ ការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ចសង្គម របស់ម្ចាស់ឆ្នោត

ឧសភា ឆ្នាំ២០១៧

**សេចក្តីផ្តើម** ៖ អត្ថបទនេះ បង្ហាញពីរូបភាពរួមនៃការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចសង្គម នៅកម្ពុជា ដែលអាចនឹងជះឥទ្ធិពលមកលើឥរិយាបថរបស់អ្នកបោះឆ្នោត។ អត្ថបទនេះនឹងផ្តោតសំខាន់ទៅលើការប្រែប្រួលនៃទម្រង់ការងារ និងការចំណាយ ព្រមទាំងប្រើប្រាស់ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចសង្គមទាំងនេះ ជាការចង្អុលបង្ហាញនៃផ្លាស់ប្តូរក្នុងសង្គម។ ក្នុងសេចក្តីសន្និដ្ឋាននៃអត្ថបទនេះ នឹងលើកអំណះអំណាងថាអ្នកនយោបាយគួរតែទទួលយកការពិតនៃការផ្លាស់ប្តូរក្នុងសង្គម និងចាប់ផ្តើមដោះស្រាយបញ្ហានយោបាយពិតប្រាកដជាក់ស្តែង ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

**ការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ចសង្គម** ៖ កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់កម្ពុជា ក្នុងអំឡុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[i] មួយផ្នែកធំគឺដោយសារតែការអភិវឌ្ឍគួរឲ្យកត់សម្គាល់ក្នុងវិស័យសំណង់ កាត់ដេរ និងសេវាកម្ម[ii] មួយវិញទៀត ក៏ឃើញមានបំលាស់ទីកម្លាំងពលកម្មដ៏ច្រើនសន្ធឹកសន្ធាប់ពីវិស័យកសិកម្ម ទៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មផងដែរ។ បំលាស់ទីនេះ ឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈការថយចុះនៃអត្រាការងារក្នុងវិស័យកសិកម្ម ចាប់ពី ៥៧,៨% នៃចំនួនប្រជាពលរដ្ឋដែលមានការងារធ្វើសរុបក្នុង ឆ្នាំ២០០៩ មកត្រឹម ៤១.៥% ក្នុង ឆ្នាំ២០១៥ ចំណែកឯក្នុងវិស័យឧស្សាហកម្ម យើងឃើញមានការកើនឡើងអត្រានៃអ្នកមានការងារធ្វើ ចាប់ពី ១៦% នៃចំនួនប្រជាពលរដ្ឋដែលមានការងារធ្វើសរុបក្នុង ឆ្នាំ២០០៩ ដល់ ២៥% ក្នុង ឆ្នាំ២០១៥ ចំណែកឯវិស័យសេវាកម្មវិញក៏កើនឡើងចាប់ពី ២៦% នៃចំនួនប្រជាពលរដ្ឋដែលមានការងារធ្វើសរុបដល់ ៣៣% ក្នុងអំឡុងពេលដូចគ្នា នេះ។[iii]

បន្ថែមពីលើនេះ ការប្រែប្រួលនៃទម្រង់ការងារ អាចមានទំនាក់ទំនងមកលើកំនើនប្រាក់ចំណូលក្នុងគ្រួសារ។ មកដល់ ឆ្នាំ២០១៥ ប្រាក់ចំណូលក្នុងគ្រួសារបានកើនឡើងប្រហែលជា ៨៥% ចាប់ពី ឆ្នាំ២០១១ ហើយប្រភពដ៏សំខាន់នៃប្រាក់ចំណូលក្នុងគ្រួសារ គឺជាប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល។[iv]

មួយវិញទៀត ក៏ឃើញមាននិន្នាការគួរឲ្យកត់សម្គាល់នៃកំណើនបរិមាណសម្ភារៈប្រើប្រាស់ ក្នុងគ្រួសារ ដូចជា ទូរសព្ទដៃ ទូរទស្សន៍ និងម៉ូតូ។ ឧទាហរណ៍ ក្នុងឆ្នាំ២០០៩ មានតែ៤៤% នៃចំនួនគ្រួសារសរុបប៉ុណ្ណោះ ដែល

ប្រសិនបើមានសំណួរទាក់ទងនឹងអត្ថបទនេះ សូមទាក់ទង កញ្ញា អេង សុខា អ្នកស្រាវជ្រាវរបស់វេទិកាអនាគត តាមរយៈ លេខទូរស័ព្ទ៖ ០១៧ ៤១៩ ០០៨ ឬ អ៊ីម៉ែល៖ info@futureforum.asia.

មានទូរសព្ទដៃប្រើប្រាស់ តែមកដល់ឆ្នាំ២០១៥ កើនឡើងដល់ទៅ ៧៧%។ ប្រហាក់ប្រហែលគ្នានោះ ក្នុងឆ្នាំ ២០០៩ មាន ៤៩% នៃចំនួនគ្រួសារសរុប បានអះអាងថាមានម៉ូតូមួយគ្រឿង ឯឆ្នាំ២០១៥ វិញ អត្រានេះកើនឡើងដល់ទៅ ៧១%។[v] ការកើនឡើងនៃសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ក៏អាចឆ្លុះបញ្ចាំងពីភាពខុសគ្នានៃផលប៉ះពាល់របស់ប្រាក់ចំណូលមកលើទម្រង់ការចំណាយរបស់ប្រជាពលរដ្ឋ រវាងអតីតកាល និងបច្ចុប្បន្នផងដែរ។ ឧទាហរណ៍ ក្នុងឆ្នាំ១៩៩០ ប្រជាពលរដ្ឋប្រហែលជាផ្តល់អាទិភាពខ្លាំងទៅលើតម្រូវការចាំបាច់ និងធានាថាពួកគេអាចមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់សមាជិកគ្រួសាររបស់ពួកគេ ខណៈដែលទម្រង់ការចំណាយក្នុងពេលបច្ចុប្បន្នហាក់ដូចជាឆ្លុះបញ្ចាំងនូវកំណើនទ្រព្យសម្បត្តិក្នុងប្រទេស ដូចដែលបាន ឆ្លុះបញ្ចាំងតាមរយៈកំណើននៃសម្ភារៈទំនើបប្រើប្រាស់ដែលគ្រួសារនីមួយៗ មាន។[vi]

ការផ្លាស់ប្តូរឥរិយាបទនៃការចំណាយ ដូចបានបង្ហាញខាងលើ ក៏មានទំនាក់ទំនងនឹងការផ្លាស់ប្តូរឥរិយាបទចំពោះវិធីដែលប្រជាពលរដ្ឋខ្ចីលុយផងដែរ។ កាលពីអតីតកាល ប្រភពសំខាន់បំផុតនៃប្រាក់កម្ចី ដែលពួកគេអាចខ្ចីបាននោះ គឺសមាជិកគ្រួសារ ឬសាច់ញាតិ។ បច្ចុប្បន្ន ប្រជាពលរដ្ឋបានងាកចេញពីវិធីសាស្ត្រនាពេលអតីតកាលដែលកាលពីមុនពឹងពាក់លើសមាជិកគ្រួសារ ទៅទទួលប្រាក់កម្ចីតាមប្រព័ន្ធផ្តល់ប្រាក់កម្ចីផ្លូវការវិញ ៖ ក្នុងឆ្នាំ ២០០៩ កម្ចី ប្រមាណ ២០,៨% នៃចំនួនប្រាក់កម្ចីសរុប បានមកពីសាច់ញាតិ ហើយតួលេខនេះថយចុះនៅត្រឹម ១០,៩% ក្នុងឆ្នាំ២០១៤។ ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ន ងាកទៅខ្ចីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកាន់តែច្រើនឡើង ៖ ក្នុងរយៈពេលដូចខាងលើ កម្ចីពីធនាគារកើនឡើងចាប់ពី ២០,៨% នៃប្រាក់កម្ចីសរុបដល់ទៅ ៤៨,៨%។[vii]

**កំណែទម្រង់ និងការរំពឹងទុករបស់ម្ចាស់ឆ្នោត** ៖ លទ្ធផលបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ២០១៣ គឺប្រៀបដូចជាការពញ្ញាក់អារម្មណ៍មួយសម្រាប់គណបក្សប្រជាជនកម្ពុជា ដែលបាត់បង់អាសនៈចំនួន ២២ ក្នុងការបោះឆ្នោតជាតិនីតិកាលទី៥។[viii] ថ្វីបើមានការដាក់បញ្ចូលអ្នកកំណែទម្រង់មួយចំនួនតូចនៅក្នុងស្ថាប័នរដ្ឋាភិបាល ដើម្បីទទួលបានការទុកចិត្ត និងការគាំទ្រពីអ្នកបោះឆ្នោតក៏ដោយ[ix] ការរំពឹងទុកពីណាក់ម្ចាស់ឆ្នោតថានឹងមានកំណែទម្រង់ជាក់ស្តែង និងការអនុវត្តការងារបានល្អប្រសើរជាងមុនរបស់មន្ត្រីរដ្ឋាភិបាល ដូចជា ការផ្តល់សេវាសាធារណៈ ជាដើម ហាក់កាន់តែកើនឡើង។ តម្រូវការនេះ ត្រូវបានរកឃើញតាមរយៈការស្រង់មតិជាសាធារណៈ ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៥ ដែលសិក្សាទៅលើមូលហេតុដែលប្រជាពលរដ្ឋសម្រេចចិត្តបោះឆ្នោតឲ្យគណបក្សនយោបាយដែលនឹងមកកាន់តំណែង ក្នុងការបោះឆ្នោតឃុំសង្កាត់ និងបោះឆ្នោតជាតិ ការស្រង់មតិនេះបានបង្ហាញថាប្រជាពលរដ្ឋជ្រើសរើសគណបក្សនយោបាយ ដោយផ្អែកលើកត្តាមួយចំនួន ដូចជា ភាពជោគជ័យរបស់គណបក្សនយោបាយក្នុងការពង្រឹងសេដ្ឋកិច្ច និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងនីតិរដ្ឋនៅក្នុងសង្គមកម្ពុជា។[x]

បន្ថែមពីលើនោះ បើយោងតាមនិន្នាការបីសំខាន់ៗ ដែលយើងកត់សម្គាល់ខាងលើ ចំណុចទីមួយ ការផ្លាស់ប្តូរកម្លាំងពលកម្ម ពីវិស័យកសិកម្ម ទៅរកការងារដែលផ្តល់ប្រាក់ខែ ក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ចំណុចទីពីរ ការកើនឡើងនៃប្រាក់ចំណូលក្នុងគ្រួសារ និងចំណុចទីបី ប្រជាពលរដ្ឋកម្ពុជាងាកមកពឹងផ្អែកលើប្រព័ន្ធផ្តល់ប្រាក់កម្ចីផ្លូវការកាន់តែច្រើនឡើង ដូចជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាជាងពឹងផ្អែកលើគ្រួសាររបស់ពួកគេ -ប្រជាពលរដ្ឋកាន់តែច្រើនឡើងនាពេលបច្ចុប្បន្ន បាននឹងកំពុងភ្ជាប់តម្រូវការរបស់ពួកគេទៅនឹងកម្មវិធីនយោបាយ ដែលសឲ្យឃើញតាមរយៈឆន្ទៈក្នុងការបោះឆ្នោតឲ្យគណបក្សនយោបាយណាដែលផ្តល់អាទិភាពលើវិស័យសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍របស់ពួកគេ។[xi]

**សេចក្តីសន្និដ្ឋាន** ៖ សង្គមកម្ពុជាកំពុងតែមានការផ្លាស់ប្តូរ ហើយខុសពីពេលណាៗទាំងអស់ ដែលប្រជាពលរដ្ឋប្រាថ្នារស់នៅក្នុងជីវិតសម្ភារៈនិយម ហើយជីវិតសម្ភារៈនិយមនោះត្រូវបានឆ្លុះបញ្ចាំង ដោយការពឹងផ្អែកមកលើស្ថាប័នធនាគារ។ យើងជឿថានិន្នាការនេះ ចុងក្រោយនឹងនាំឲ្យមានការចាប់អារម្មណ៍កាន់តែច្រើនឡើងពីសំណាក់ប្រជាពលរដ្ឋ មកលើគោលនយោបាយ របស់គណបក្សនយោបាយនានា[xii] ជាពិសេសស ប្រសិនបើកម្មវិធីនយោបាយត្រូវបានមើលឃើញថា មានឥទ្ធិពលមកលើសេដ្ឋកិច្ចឯកជន។ ឧទាហរណ៍ តាមរយៈការស្រាវជ្រាវថ្មីៗ បានចង្អុលបង្ហាញថា ការចែកអំណោយដែលធ្លាប់បានអនុវត្តកន្លងមក ហើយត្រូវបានគេមើលឃើញថាជាការទិញសន្លឹកឆ្នោតនោះ គឺជាវិធីសាស្ត្រដែលមិនបានផល[xiii] ព្រោះថាប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ន វាយតម្លៃគណបក្សនយោបាយណាមួយ តាមស្ថានភាពសេដ្ឋកិច្ចគ្រួសារពួកគេ។[xiv] ដូច្នេះ អ្វីដែលសំខាន់នោះគឺ អ្នកនយោបាយគួរតែពិចារណាឲ្យដិតដល់ ចំពោះការផ្លាស់ប្តូរក្នុងសង្គម និងតាក់តែងកម្មវិធីនយោបាយ ឬគោលនយោបាយប្រាកដនិយម ដែលឆ្លុះបញ្ចាំងពីតម្រូវការរបស់ប្រជាពលរដ្ឋ ឧទាហរណ៍ កម្មវិធីនយោបាយដែលធ្វើឡើងតាមរយៈការពិចារណាលើការផ្លាស់ប្តូរនៃសកម្មភាពសេដ្ឋកិច្ចរបស់ម្ចាស់ឆ្នោត។

---

[i] ធនាគារអភិវឌ្ឍអាស៊ី "សេដ្ឋកិច្ចកម្ពុជា" ចូលអាន ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៧ http://bit.ly/2mIYAKy.

[ii] ធនាគារពិភពលោក (២០១៦) "បង្កើនលទ្ធភាពប្រកួតប្រជែងការនាំចេញ ៖ គន្លឹះសំខាន់សម្រាប់ភាពជោគជ័យផ្នែកសេដ្ឋកិច្ចនាពេលអនាគតរបស់កម្ពុជា" ការបន្ទាន់សម័យពីសេដ្ឋកិច្ចកម្ពុជា។

[iii] សូមបញ្ជាក់ថាអត្ថបទនេះ ប្រើប្រាស់ទិន្នន័យពីរបាយការណ៍នៃការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ទាំងឆ្នាំ២០១៤ និងឆ្នាំ២០១៥ របស់ វិទ្យាស្ថានជាតិស្ថិតិ ដោយសារតែទិន្នន័យនៃចំនួនប្រជាពលរដ្ឋដែលមានការងារធ្វើក្នុងឆ្នាំ២០០៩ ពុំមានក្នុងរបាយការណ៍ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១៥។ របាយការណ៍ឆ្នាំ២០១៤ អាចរកបាន ៖ http://bit.ly/2mmx1q9 ចំណែកឯរបាយការណ៍ឆ្នាំ២០១៥ ពុំទាន់បានដាក់នៅលើគេហទំព័រនោះទេ។

[iv] វិទ្យាស្ថានជាតិស្ថិតិ (២០១៦) "ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា" ទំព័រ ៧០។

[v] ដូចខាងលើ ទំព័រ ៨៤

[vi] ស្ទូលីវ៉ាន់ មីខាអែល "ការបោះឆ្នោតនៅកម្ពុជា ៖ លទ្ធិប្រជាធិបតេយ្យ អាជ្ញាធរ និងការគាំទ្រពីអន្តរជាតិសម្រាប់ការបោះឆ្នោត ឆ្នាំ១៩៩៣-២០១៣" (សារព័ត៌មាន NIAS ប្រទេសដាណឺម៉ាក ឆ្នាំ២០១៦) ទំព័រ ២៧០។

[vii] វិទ្យាស្ថានជាតិស្ថិតិ (២០១៥) "ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១៤" ទំព័រ ៩៩ http://bit.ly/2mmx1q9.

[viii] ប៉ូញៀ ខេវីន "ការបោះឆ្នោតជា ការពញ្ញាក់អារម្មណ៍ សម្រាប់គណបក្សប្រជាជនកម្ពុជា" *ឌឹ ភ្នំពេញ ប៉ុស្តិ៍*២៤ ខែមិថុនា ឆ្នាំ២០១៤ http://bit.ly/2nqF4m3.
[ix] វេទិកាអនាគត "ទិដ្ឋភាពរួម និងការវិភាគលើស្ថានភាពនយោបាយនៅកម្ពុជាបច្ចុប្បន្ន ក្នុង២០១៦" (២០១៧) http://bit.ly/2hWTdce.
[x] បាបូរីក ម៉ារីថា និងវូកូវីក ដានីឡូ (២០១៦) "ប្រទេសកម្ពុជា៖ ការអង្កេតលើយុទ្ធសាស្ត្រទ្រទ្រង់ជីវិភាព និងការរំពឹងទុកសម្រាប់អនាគត" (*មូលនិធិអាស៊ី*) http://bit.ly/2ncjmpV.
[xi] ដូចខាងលើ
[xii] ប្រោន គ្រីស្តុបហ្វ័រ (២០០៩) "ការចេញផ្សាយសង្ខេប ៖ ឥរិយាបទបោះឆ្នោតផ្អែកលើស្ថានភាពសេដ្ឋកិច្ចសង្គម"។
[xiii] អ៊ីខលមែន ដេល អែហ្វ (២០១៧) "ការសិក្សាពីនយោបាយ និងសេដ្ឋកិច្ចសង្គម ក្នុងមជ្ឈិមបូព៌ា និងអាស៊ី" ទំព័រ ៨៥ http://bit.ly/2nCJr1g.
[xiv] បាបូរីក ម៉ារីថា និងវូកូវីក ដានីឡូ (២០១៦) "ប្រទេសកម្ពុជា៖ ការអង្កេតលើយុទ្ធសាស្ត្រទ្រទ្រង់ជីវិភាព និងការរំពឹងទុកសម្រាប់អនាគត" (*មូលនិធិអាស៊ី*) http://bit.ly/2ncjmpV.